**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
លេខ:......៦៩៦.............កល.អរហ.បន្ទ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃស្តីពីការងារថែទាំ និងជួសជុលរថយន្ត ចំនួន២០គ្រឿង សម្រាប់ឆ្នាំ២០១៨

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងបរិស្ថាន សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ក្រសួងបរិស្ថាន នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារថែទាំ និងជួសជុលរថយយន្តចំនួន២០គ្រឿង សម្រាប់ឆ្នាំ២០១៨។

ក្រុមលទ្ធកម្ម នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅក្រុមលទ្ធកម្ម នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដែលមានអាសយដ្ឋានអគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី...១០.........ខែ ..សីហា...ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនក្រុមលទ្ធកម្ម នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី....១០.....ខែ...កញ្ញា.....ឆ្នាំ២០១៨ វេលាម៉ោង .៨.ៗ.៤៥........នាទី។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅក្រុមលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ..៨ៗ.៤៥..........នាទី ថ្ងៃទី...១០.......ខែ..កញ្ញា.......ឆ្នាំ២០១៨។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្ម នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃព្រហស្បតិ៍.១៣រោចខែស្រាពណ៍.សាលឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ..០៩....ខែ ..សីហា...ឆ្នាំ២០១៨
**អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមលទ្ធកម្ម**

ជ្រិន_សុខា

**ចម្លងជូន**
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
"អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ"
-អង្គភាពប្រឆាំងអំពើពុករលួយ

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
ក្រុមលទ្ធកម្ម